# ជូនចំពោះមិត្តទាំងឡាយ

នៅថ្ងៃអាទិត្យទំនុកតម្កើង ( ថ្ងៃអាទិត្យមុនថ្ងៃអាទិត្យបុណ្យអ៊ីស្ទើរ ) ឆ្នាំនេះ គឺប៉ះចំថ្ងៃអាទិត្យចុងក្រោយក្នុងខែមីនា ។ នោះគឺជាពេលដែលយើងប្រារព្ធថ្ងៃដែលព្រះយេស៊ូវបានគង់លើលាចូលទៅក្នុងទីក្រុងយេរូសាឡិម ។ ប្រជាជនបានបក់ស្លឹកត្នោត ហើយបានស្រែកថា « ហូសាណា ! » ពីរបីថ្ងៃក្រោយមក ព្រះយេស៊ូវបានរងទុក្ខ និងបានសុគតសម្រាប់យើង ។ បន្ទាប់មក ទ្រង់បានមានព្រះជន្មរស់ឡើងវិញ ! យើងសង្ឃឹមថា អ្នកនឹងរីករាយជាមួយពេលវេលាដ៏ពិសេសនេះ ដើម្បីចងចាំអ្វីដែលព្រះវរបិតាសួគ៌ និងព្រះយេស៊ូវបានធ្វើសម្រាប់យើង ( សូមមើល យ៉ូហាន ៣:១៦ ) ។ ដោយសារពួកទ្រង់ នោះយើងនឹងរស់ម្តងទៀត !

ដោយក្តីស្រឡាញ់

ទស្សនាវដ្តី ប្រិយមិត្ត

បន្ថែម តើមានប៉ុន្មានទំព័រអំពីព្រះយេស៊ូវដែលអ្នកអាចរកឃើញនៅក្នុងច្បាប់នេះ ?






## កន្លែងដែលយើងអានទស្សនាវដ្តី *ប្រិយមិត្ត*

យើងចូលចិត្តអានទស្សនាវដ្តីប្រិយមិត្ត ! វាជួយយើងឲ្យមានអារម្មណ៍មិនសូវឯកោ ដោយសារមានតែយើងប៉ុណ្ណោះដែលជាសមាជិកសាសនាចក្រនៅក្នុងទីក្រុងយើង ។ យើងអានវាជាភាសាអាល្លឺម៉ង់ និងជាភាសាហូឡង់ ដោយសារម៉ាក់យើងមកពីប្រទេសហូឡង់ ហើយប៉ាយើងមកពីប្រទេសអាល្លឺម៉ង់ ។

**ឡាស និងថូបិន អេស អាយុ ៥ និង ៣ ឆ្នាំ ទីក្រុង ឡូវ៉រ សាហ្សូនី ប្រទេសអាល្លឺម៉ង់**




## យើងចូលចិត្តមើលព្រះវិហារបរិសុទ្ធ

យើងរស់នៅជិតព្រះវិហារបរិសុទ្ធបារ៉ានហ្គីលឡាកូឡុំប៊ី ហើយទៅព្រះវិហារបរិសុទ្ធរៀងរាល់ពីរសប្តាហ៍ម្តង ។ វាជួយយើងឲ្យចងចាំពីសេចក្តីសញ្ញាទាំងឡាយដែលយើងនឹងធ្វើជាមួយព្រះវរបិតាសួគ៌ ។

**ថ្នាក់បឋមសិក្សាសាខាភើតូកូឡុំប៊ី ប្រទេសកូឡុំប៊ី**



## សង់សំពៅរបស់អ្នកផ្ទាល់

ខ្ញុំបានរៀនពីរបៀបដែលនីហ្វៃបានសង់សំពៅមួយ ( ខែ កុម្ភៈ ឆ្នាំ ២០២០ ) ដូច្នេះ ខ្ញុំចង់សង់សំពៅមួយរបស់ខ្ញុំដែរ ដើម្បីយល់ពីអារម្មណ៍របស់នីហ្វៃ ។ ពីដំបូងវាពិបាក ប៉ុន្តែខ្ញុំបានរៀនមិនបោះបង់ និងទុកចិត្តលើព្រះអម្ចាស់ដូចជានីហ្វៃបានធ្វើ ។

**អៀន ឌី អាយុ ៩ ឆ្នាំ វីរ៉ាគ្រូស្ស មិកស៊ីកូ**